# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០២០

## អូស្ត្រាលីរួមចំណែកក្នុងកិច្ចប្រឹងប្រែងជួយសង្គ្រោះគ្រោះទឹកជំនន់

ថ្ងៃនេះ ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅកម្ពុជា ឯកឧត្តម Pablo Kang បានធ្វើដំណើរទៅកាន់ខេត្តកំពង់ធំដើម្បីគាំទ្រដល់កិច្ចប្រឹងប្រែងជួយសង្គ្រោះគ្រោះទឹកជំនន់ ដែលរៀបចំដោយ គណៈកម្មាធិការជាតិ គ្រប់គ្រងគ្រោះមហន្តរាយ ក្រោមអធិបតីភាព ឯកឧត្តម ឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត។

កសិករជាង៦០០០នាក់ នៅខេត្តកំពង់ធំ បានរងគ្រោះដោយសារគ្រោះទឹកជំនន់ធ្ងន់ធ្ងរ ក្នុងឆ្នាំនេះ ហើយដំណាំចំនួន ១២ ០០០ហិកតា ត្រូវបានបំផ្លាញ។ នេះគឺជាការខាតបង់ដ៏ធំសម្រាប់កសិករកម្ពុជា បន្ថែមទៅលើការប៉ះពាល់ផ្នែកសេដ្ឋកិច្ចរួចទៅហើយ ដោយសារជម្ងឺកូវីដ១៩។

គណៈកម្មាធិការជាតិ គ្រប់គ្រងគ្រោះមហន្តរាយកម្ពុជា កំពុងចែកចាយពូជស្រូវជូនដល់កសិករសម្រាប់ការដាំដុះនៅរដូវក្រោយនេះ។ ដើម្បីចូលរួមចំណែកក្នុងកិច្ចការនេះ រដ្ឋាភិបាលអូស្ត្រាលី តាមរយៈ កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា-អូស្ត្រាលី (CAVAC) ផ្តល់អំណោយជាម៉ាស៊ីនដាំគ្រាប់ពូជស្រូវឈ្មោះ Eli Seeder ចំនួន២០គ្រឿង ជូនដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត សម្រាប់កសិករប្រើប្រាស់នៅក្នុងខេត្តនេះ។ ម៉ាស៊ីនដាំគ្រាប់ពូជស្រូវដែលបង្កើតឡើងដោយស្នាដៃកម្ពុជានេះ អាចកាត់បន្ថយបរិមាណពូជស្រូវ ដែលកសិករត្រូវការក្នុងការដាំដុះ ជួយកសិករសន្សំរហូតដល់ ២៥០ដុល្លារក្នុងមួយហិកតា និងកំលាំងពលកម្មស្មើនឹង៥០ថ្ងៃ ហើយអាចបង្កើនទិន្នផលបានខ្ពស់ទៀតផង។

នេះគឺជាផ្នែកមួយនៃការរួមចំណែករបស់អូស្ត្រាលី ដល់កិច្ចប្រឹងប្រែងជាច្រើន ក្នុងការជួយសង្គ្រោះគ្រោះទឹកជំនន់ ដែលមានតំលៃស្មើនឹងថវិកា ៨០ ០០០ដុល្លារ។ តាមរយៈកម្មវិធី ACCESS រដ្ឋាភិបាលអូស្ត្រាលីនឹងចែកចាយអាហារ និងសម្ភារៈអនាម័យ ដល់ ១ ០០០ គ្រួសារ ដែលមានសមាជិក ជាជនដែលមានពិការភាព។ សហការជាមួយសមាគមទឹកអូស្ត្រាលី កម្មវិធី3i កំពុងតែរៀបចំជាបន្ទាន់ក្នុងការបំពាក់ ប្រព័ន្ធសំអាតទឹកដែលមានសមត្ថភាពខ្ពស់ នៅតាមមណ្ឌលសុខភាពនានា ក្នុងតំបន់រងផលប៉ះពាល់។

ឯកអគ្គរាជទូត Kang បានមានប្រសាសន៍ថា "ក្នុងនាមជាប្រទេសមួយ ដែលងាយនឹងរងគ្រោះដោយភាពរាំងស្ងួត និងទឹកជំនន់ យើងដឹងថា គ្រោះមហន្តរាយធម្មជាតិ អាចបំផ្លិចបំផ្លាញសហគមន៍ច្រើន យ៉ាងណា។"

"ក្នុងនាមជាមិត្ត និងអ្នកជិតខាង យើងចង់ធ្វើអ្វីដែលយើងអាចធ្វើបាន ដើម្បីជួយប្រជាជនកម្ពុជា ឱ្យវិលត្រឡប់ទៅស្ថានភាពដើមរបស់ពួកគេវិញ បន្ទាប់ពីទឹកជំនន់ ដូចដែលយើងធ្លាប់បានធ្វើ បន្ទាប់ពីគ្រោះមហន្តរាយធម្មជាតិមុនៗ នៅក្នុងប្រទេសកម្ពុជា។ ការជួយកសិករ ត្រៀមរៀបចំសម្រាប់រដូវដាំដុះបន្ទាប់ នឹងធានាថា ពួកគេអាចចាប់ផ្តើម ធ្វើឱ្យជីវភាពរស់នៅរបស់ពួកគេ ត្រឡប់មកដូចមុនវិញ។"

ប្រទេសអូស្ត្រាលីបាននិងកំពុងជួយ ដល់ការអភិវឌ្ឍកសិកម្មនៅកម្ពុជា អស់រយៈពេលជាង ២៥ ឆ្នាំមកហើយ។

**ទំនាក់ទំនងព័ត៌មាន៖** Australian.Embassy.Cambodia@dfat.gov.au